# របៀបសន្ទនា
# ដោយខ្លាហាន



#SEE ALL THE PEOPLE
RESOURCES

# សេចក្តីផ្តើម

បើអ្នកដូចខ្ញុំ គ្រាន់តែអ្នកគិតពីការសន្ទនាដែលលំបាក នោះអ្នកអាចបញ្ជូនសញ្ញាការចៀសពីជម្លោះភ្លាម។ នេះគឺជាការដែលត្រូវនិយាយជាមួយប្តីប្រពន្ធពីសេចក្តីត្រូវការ ដែលយើងមិនអាចបំពេញបាន មែនទេ? មិនបាច់ក៏បានដែរ អរគុណ។ នេះគឺជាការដែលយើងត្រូវនិយាយជាប្រធាន ឬអ្នកធ្វើការជាមួយពីបញ្ហាមិនល្អក្នុងការិយាល័យ ដែលពាក់ពន្ធ័ គាត់នោះ មែនទេ? សូមពួនសិនហើយ។ នេះគឺជាការដែលខ្ញុំ ត្រូវនិយាយពីអត្តចរិកមិនល្អរបស់ពួកម៉ាកខ្ញុំ មែនទេ? សូមចៀសសិនហើយ។ នេះគឺជាការដែលក្រុមជំនុំត្រូវមាន«សន្ទនាដ៏វិសុទ្ធ»ពី បញ្ហាអន្តោប្រវេស ផ្លូវភេទ ឬបញ្ហាសង្គម មែនទេ? សូមរំលងហើយ។

យើងគ្រប់រូប មានវិធីល្អ និងមិនល្អ ក្នុងការដោះស្រាយជម្លោះ។ ប៉ុន្តែការដែលយើងរីកលូតលាស់ក្នុងព្រះគ្រីស្ទ ទាមទារឲ្យយើងមានការសន្ទនាដែលលំបាក។ វាកើតឡើងក្នុងទំនាក់ទំនងគ្រួសារ និងក្នុងក្រុមជំនុំរបស់យើងដែរ។ ការរៀនគ្រប់គ្រងអារម្មណ៍របស់យើង ការដែលយើងអាចនិយាយដោយមានការគោរព ជាមួយអ្នកដែលមានគំនិតខុសពីយើង ឬមានបញ្ហារដែលមិនអាចដោះស្រាយបាន ហើយនិងការដែលយើងត្រូវប្រកាន់ភ្ជាប់នូវគំនិតរបស់យើង មិនមែនជាជំនាញដែលយើងមានតាំងពីកំណើតនោះទេ។ លើសពីការដែលយើងរៀនពីជំនាញថ្មី ការសន្ទនាពិបាកៗ គឺជាផ្នែកសំខាន់ៗក្នុងការរីកលូតលាស់ ក្នុងព្រះយេស៊ូវគ្រីស្ទ។ បទពិសោធន៍ជាក្រុម ក្នុង «សន្ទនាដ៏វិសុទ្ធ» បង្កើតឱកាសសំរាប់ការសន្ទនា និងការពិចារណា ដែលអាចជួយឲ្យយើងយល់កាន់តែច្បាស់ពីខ្លួនឯង និងព្រះ។

ការដែលយើងអាចបង្ហាញពីការ គ្រប់គ្រងខ្លួនឯង សេចក្តីមេត្តា និងព្រះគុណ ក្នុងពេលតានតឹង គឺជាការបង្ហាញពីភាពពេញវ័យក្នុងព្រះគ្រីស្ទ។ បើតាម សភាវគតិរបស់យើង យើងប្រហែលជាត្រូវរត់ភាសខ្លួន ឬនៅទ្រឹងមួយកន្លែង ឬ ត្រូវវាយបក តែការដែលយើងរៀននិយាយពីការទាំងនេះ ក្នុងនាមជា សិស្សរបស់ព្រះគ្រីស្ទ យើងអាចទទួលបានការប្រោសឲ្យជា និងការផ្សះផ្សារ។ ក្នុងវប្បធ៌មដែលពេញដោយការឈ្នះចាញ់ ការជជែកដេញដោល ជាជាង ការសន្ទនា សេចក្តីភ័យខ្លាច និងការបែងចែកក្នុងរបបនយោបាយ ក្រុមជំនុំមាន ឪកាសក្នុងការបង្កើតសិស្ស ដែលមានបំណងចង់សន្ទនាពីប្រធានបទដែលពិបា កៗ ហើយធ្វើជាឧទាហរណ៍ដល់ពិភពលោក ក្នុងការមិនយលស្របដោយ សេចក្តីស្រឡាញ់។

កូនសៀវភៅនេះ គឺជាការអញ្ជើញអ្នក និងក្រុមជំនុំរបស់អ្នក រៀនពីជំនាញ និង ទុកចិត្តលើព្រះវត្តមាននៃព្រះគុណរបស់ព្រះ ក្នុងពេលដែលយើងធ្វើការសន្ទនា ដោយសេចក្តីខ្លាហាន។

# ផ្ទះរបស់ណាថាញ៉ែល

មិនមានមនុស្សច្រើនទេ ដែលចាត់ទុកលោកណាថាញ៉ែល ជាសាវក្យកំពូល ទាំង៥ ក្នុងចំណោមសាវក្យទាំង១២នោះទេ។ តែសំនួររបស់ណាថាញ៉ែលគឺជា ឧទាហរណ៍នៃការសន្ទនាដោយភាពខ្លាហាន។ គាត់សួរភីលីពថា «តើមានអ្វីល្អ ដែលកើតមានក្នុងភូមិណាសារ៉ែត?» (យ៉ូហាន១៖៤៦)។ សំនួររបស់ណាថា ញ៉ែល បង្ហាញអំពីគាត់និងយើងគ្រប់គ្នា។

បើមើលត្រលប់ក្រោយវិញ វាងាយណាស់ក្នុងការសើចចំអកដល់ណាថាញ៉ែល ដែលបដិសេធន៍ព្រះគ្រីស្ទអ្នកភូមិណាសារ៉ែត។ តែការសង្ស័យរបស់គាត់ មានហេតុផលត្រឹមត្រូវ។ ណាសារ៉ែត គ្មានអ្វីសំខាន់ទេ។ ភូមិនេះមិនមានក្នុង

ផែនទីផង។ បើសម័យនោះមានGPS ប្រហែលវាមិនអាចនាំផ្លូវក្នុងភូមិដ៏តូច នោះបានទេ។ ក្នុងគំនិតរបស់ណាថាញ៉ែល វាទៅមិនរួចទេ ដែលព្រះសង្គ្រោះលោក មកចាប់កំណើតក្នុងភូមិដែលគ្មានសារៈសំខាន់នេះ។

ដែលលោកភីលីពប្រាប់ណាថាញ៉ែលថាគាត់បានរកឃើញព្រះមួយអង្គដែលបានចែងទុកក្នុងគម្ពីរសញ្ញាចាស់  នោះគួរឲ្យអស់សំណើច។ បើណាថាញ៉ែលនៅតែសង្ស័យ ហើយមិនទទួលសំណើររបស់ ភីលីពឲ្យ «មកមើល» នោះគាត់នឹងមិនបានជួយព្រះគ្រីស្ទទេ។ ព្រះគ្រីស្ទបានកែប្រែអនាគតរបស់គាត់ ហើយទ្រង់ក៏ជាតួអង្គសំខាន់បំផុតក្នុងប្រវត្តិគ្រីស្ទាន។

ពេលដែលយើងគិតថា វាស្រួលជាងក្នុងការដែលយើងចាត់ទុកខ្លួនឯងជាពេត្រុស ខ្ញុំលើកទឹកចិត្តឲ្យយើង គិតថាយើងគឺជាលោកណាថាញ៉ែល។ ការសង្ស័យ និងការមើលឃើញអាក្រក់ គឺចាក់ឫស ក្នុងប្រជាជនអាមេរិក។ ការស្ទង់មតិថ្មីៗនេះរកឃើញថា ប្រជាជនមិនជឿលើមន្ត្រីរាជការទេ។ ការបែកបាក់ផ្នែកនយោបាយ ធ្វើឲ្យមនុស្សមិនមានការទុកចិត្តចំពោះអ្នកដែលមិនមានគំនិតដូចគ្នា។ រឿងនេះក៏ដូចនិងការងារព្រះដែរ។ ក្នុងក្រុមជំនុំយូណៃធីតមេថូឌីស្ទ មនុស្សគ្រប់រូប គិតថាគេដើរតាមលោកចន វេស្លី។ ម្នាក់ៗប្រើព្រះគម្ពីរជាអំណះអំណាងគំនិតរបស់គេ។ លទ្ធផលគឺយើងបានច្រានចោលគំនិតអ្នក ដែលកំពុងថ្វាយបង្គំជាមួយយើង ហើយចង់ចូលរួមបេសកកម្មក្នុងពិភពលោក។ អាក្រក់ជាងការដែលយើងមិនចុះសម្រុងគ្នាក្នុងសេចក្តីស្រឡាញ់ គឺយើងគ្មានសេចក្តីអាណិតចំពោះអ្នកដែលយើងត្រូវស្រឡាញ់ និងបំរើ។ យើងមិនត្រឹមតែមិនធ្វើជាគម្រូរនៃ «ការរួបរួម សិរីភាព និងសេចក្តីស្រឡាញ់»ទេ គឺយើងថែមទាំងបែកបាក់គ្នាទៀត។ យើងសួរគ្នាថា «តើពួកគណៈបក្សប្រជាធិបតេយ្យធ្វើអីល្អទេ? ចុះពួកសាធារណៈរដ្ឋ? ពួកសេរីនិយម? ពួកអភិរៈនិយម? ពួកមកពីរដ្ឋខាងជើង? ។ល។»

ពេលដែលលោកណាថាញ៉ែលភ្ញាក់ផ្អើលចំពោះពាក្យរបស់ភីលីព ដែលថាសាស្រ្តណាសារ៉ែត គឺជាព្រះសង្គ្រោះ លោកណាថាញ៉ែល ត្រូវតែហ៊ានទម្លាក់ចោលគំនិតចាស់របស់គាត់។ ការបោះចោលគំនិត និងជំនឿចាស់ វាត្រូវការ

ការតាំងចិត្តច្រើនណាស់។ វាត្រូវការសេចក្តីខ្លាហាន ចូលមកកាន់ទីមិនជាក់លាក់មួយ។ តែយើងឃើញមានមនុស្សច្រើនណាស់ក្នុងព្រះគម្ពីរ ដែលត្រូវឆ្លងកាត់ពីការភ្ញាក់ផ្អើល មកកាន់ទីមិនជាក់លាក់ ហើយមកកាន់សេចក្តីជំនឿ ហើយមកកាន់ការដឹកនាំរបស់ព្រះ (អាប្រាហាំ ម៉ូសេ អេលីយ៉ា ប៉ូល និង ហេព្រើរ១១)។ ជារឿយៗ ពេលយើងហ៊ានបោះចោលការគិតរបស់យើង គឺនាំឲ្យយើងចូលមកកាន់ព្រះគុណរបស់ព្រះ ដូចជាអ្វីដែលលោកណាថាញ៉ែលបានធ្វើ។

គោលបំណងរបស់កូនសៀវភៅនេះ ជួយឲ្យមនុស្សចេញពីការសង្ស័យ ទៅកាន់ការបើកចំហរ និងការជួបព្រះគុណព្រះ។ ការចូលរួមក្នុងការសន្ទនាលំបាកៗ ធ្វើឲ្យយើងមានសេចក្តីខ្លាហាន ឈ្នះលើសេចក្តីភ័យខ្លាច ហើយចូលរួមជាមួយមនុស្សដែលយើងចង់បដិសេធន៍។ សូម្បីតែក្នុងការសន្ទនាសម័ញ្ញៗ ក៏យើងឃើញមានបញ្ហាដែលធ្វើឲ្យយើងមិនស្តាប់គ្នា។ កត្តានេះក៏ធ្វើឲ្យយើងមិនផ្តល់តំលៃដល់សមាជិកក្នុងក្រុមជំនុំរបស់យើង និងធ្វើឲ្យយើងមើលមិនឃើញរូបអង្គព្រះក្នុងអ្នកដទៃ។

ការដែលយើងបើកចំហរចំពោះសំឡេងរបស់ព្រះ ដោយការដែលយើងស្តាប់ អាចធ្វើឲ្យយើងចូលរួម ក្នុងតុសន្ទនា។ សូមឲ្យយើងដូចជាលោកណាថាញ៉ែល ហ៊ានជួបជាមួយព្រះគុណរបស់ព្រះ ដែលនៅក្នុងចំណោមពួកយើង។

# គំរូព្រះគ្រីស្ទ

ព្រះគ្រីស្ទបានរួមចំណែកក្នុងការសន្ទនាដ៏ខ្លាហាន។ ទ្រង់បានបន្ទោសលោកពេត្រុស និងសាវក្សដទៃទៀត ច្រើនដង។ ទ្រង់បានសួរដេញដោលគ្រួសាររបស់ទ្រង់។ ទ្រង់តែងប្រកែកជាមួយការបកស្រាយរបស់អ្នកដឹកនាំសាស្រ្តយូដា។ ហើយទ្រង់ក៏ប្រឈមមុខជាមួយការល្បួងរបស់សាតាំងដែរ។

ព្រះគម្ពីរយ៉ូហាន កត់ត្រាពីពេលមួយដែលព្រះយេស៊ូវស្ថិតក្នុងជម្លោះ។ អ្នកដឹកនាំសាស្ត្រយូដា បាននាំស្ត្រីម្នាក់ដែលផិតប្តី។ តើព្រះយេស៊ូវធ្វើតាមច្បាប់ដែលតម្រូវឲ្យសម្លាប់ស្ត្រីនោះដោយដុំថ្ម ឬទ្រង់ត្រូវមានចិត្តមេត្តា ដោយដោះលែងស្ត្រីនោះ? អ្នកដឹកនាំសាស្ត្រយូដា បានបង្កើតរឿងនេះឡើងដើម្បីរកទោសដាក់ព្រះយេស៊ូវ។

អ្នកប្រហែលចាំរឿងនេះ។ ព្រះគ្រីស្ទអោនចុះ ហើយសរសេរលើខ្សាច់។ ប្រហែលព្រះគ្រីស្ទកំពុងអធិស្ឋានទៅកាន់ព្រះវបិតា និងព្រះវិញ្ញាណបរិសុទ្ធ ក្នុងពេលដែលទ្រង់កំពុងស្វែងរកចំលើយ។ ជីវិតរបស់ស្ត្រីម្នាក់ស្ថិតក្នុងការសំរេចចិត្តរបស់ព្រះយេស៊ូវពេលនេះ «បើអ្នកណាម្នាក់ក្នុងចំនោមពួកអ្នក គ្មានបាបសោះ សូមចោលដុំថ្មមុនគេចុះ» (យ៉ូហាន ៨៖៧)

យើងរៀនបានច្រើនណាស់ពីចម្លើយមួយនេះរបស់ព្រះគ្រីស្ទ។ យើងរៀនបានទៀត ពេលដែលព្រះគ្រីស្ទចាប់ផ្តើមនិយាយជាមួយស្ត្រីនោះ។ ទ្រង់បានចាប់ផ្តើមការសន្ទនាដោយសួរទៅនាងនោះថា «នាងអើយ តើពួកគេទៅណាហើយ? មានអ្នកណាកាត់ទោសនាងទេ?» ព្រះគ្រីស្ទបានជួយសង្គ្រោះជីវិតរបស់នាង ហើយទ្រង់បានអនុញ្ញាតិឲ្យនាងនិយាយ។ ព្រះគ្រីស្ទផ្តល់អំណាចដល់សំដីរបស់នាង។

ព្រះគ្រីស្ទបានបង្ហាញជំរើសផ្សេង។ ព្រះគ្រីស្ទប្រើសេចក្តីពិត និងព្រះគុណ ក្នុងការដោះស្រាយជាមួយ អ្នកដឹកនាំសាស្ត្រយូដា និងស្ត្រីនោះ ដោយទ្រង់បានឆ្លើយថា «ខ្ញុំមិនកាន់ទោសអ្នកទេ។ សូមទៅចុះ ហើយចាប់ពីពេលនេះទៅសូមកុំប្រព្រឹត្តអំពើបាបទៀត។»

តើអ្នកធ្វើយ៉ាងណា បើអ្នកស្ថិតក្នុងស្ថានភាពរបស់ព្រះគ្រីស្ទ? តើអ្នកនឹងអនុវត្តច្បាប់ ហើយឲ្យស្ត្រីនោះស្លាប់? តើអ្នកនឹងផ្តល់សេចក្តីមេត្តា ដោយរំលងច្បាប់? ជារឿយៗ សង្គមរបស់យើងជ្រើសរើសចំនុចមួយ ដោយមិនប្រកាន់ផ្លូវកណ្តាល។ ព្រះគ្រីស្ទដ៏ជាព្រះ ទ្រង់បានប្រើព្រះគុណ និងសេចក្តីពិត។

ការដែលយើងសន្ទនាដោយសេចក្តីខ្លាហាន តម្រូវឲ្យយើងប្រើព្រះគុណ និង សេចក្តីពិត ហើយបើក ឲ្យព្រះវិញ្ញាណជាអ្នកដឹកនាំ។ ពេលយើងធ្វើការសន្ទនា យើងជឿថា ដៃគូសន្ទនារបស់យើងគឺជាកូនព្រះ។ ការដែលយើងធ្វើការសន្ទនា ដោយសេចក្តីខ្លាហាន គឺយើងកំពុងរីកចំរើនពេញវ័យក្នុងព្រះគ្រីស្ទយេស៊ូវ។

# ការសន្ទនាខ្លាហាន ជាទីរីកធំធាត់ក្នុងព្រះគ្រីស្ទ

ការរីកធំធាត់ក្នុងព្រះគ្រីស្ទ ទាមទារឲ្យយើងរៀន (សាវក្ស គឺអ្នករៀន)។ ជាមនុស្សពេញវ័យ យើងមានតួនាទីសកម្ម ក្នុងការរៀនពីអ្វីដែលយើងត្រូវការក្នុងជីវិត។ ពេលយើងជួបការភ័យភិត ក្នុងពេលដែលយើងមានការសន្ទនាលំបាក នោះយើងនឹងឆ្លើយតបដោយកាយវិការ «វាយបក នៅទ្រឹង ឬរត់»។ ការឆ្លើយតបទាំងបីនេះ ធ្វើឲ្យបញ្ហាកាន់តែធំ ហើយយើងមិនរៀនបានអ្វីសោះ។ យើងមិនបើកចិត្តរៀន បែរជាយើងជ្រើសរើសយកការការពារខ្លួន និងការវាយបក។

កាយវិការដូចជា ការស្គាល់ខ្លួនឯង ការពិចារណាពីខ្លួនឯង និងការចង់រៀន គឺទាមទារការរៀនពីការរីកចំរើនក្នុងព្រះគ្រីស្ទ។ ឧបសគ្គធំបំផុតក្នុងក្រុមជំនុំ គឺជាការបង្កើតទីកន្លែងសុវត្ថិភាពក្នុងការរៀន។ ឧបសគ្គធំបំផុត គឺជាការដែលយើងមកកន្លែងសន្ទនាដោយផ្ទាប់ជាមួយគំនិតថា «ខ្ញុំត្រូវ» ឬ «ខ្ញុំឈ្នះ» ឬ «ការការពារគំនិតខ្លួនឯង»។ គេប្រហែលជាភ័យខ្លាចថាការសន្ទនា នឹងផ្តល់លទ្ធផលនៃការបែកបាក់។

ការបង្កើតបរិស្ថានសុវត្ថិភាពក្នុងការរៀនគឺជាកត្តាសំខាន់ តែវាក៏លំបាកដែរ។ វាទាមទារការ ស្វាគមន៍ ព្រះគុណ និងសេចក្តីពិត និងការផ្តល់តំលៃដល់

អំណោយទានរបស់អ្នកដទៃ និងគំនិតដែលយើងត្រូវរៀនបន្ទាបខ្លួន។

ដើម្បីរៀនបានស៊ីជម្រៅ គ្រប់គ្នាត្រូវតែជឿថាសំឡេងរបស់ខ្លួនឯង នឹងទទួលបានការស្តាប់និងគោរព។ កេរ្តិ៍តំណែលរបស់មេថូឌីស្ទ គឺជាការបង្ហាញ ការបន្ទាបខ្លួន និងការជំរុញគ្នាមករកសេចក្តីស្រឡាញ់។ ក្នុងអត្ថបទរបស់លោកចនវេស្លី ដែលមានចំណងជើងថា "A Plain Account of Christian Perfection" គាត់បានសរសេរថា «គ្មានសេចក្តីស្រឡាញ់មួយណា ដែលគ្មានការអត់ធ្មត់នោះទេ ហើយក៏គ្មានការអត់ធ្មត់ណាដែលគ្មានការបន្ទាបខ្លួន និងភាពផ្អែមល្ហែមរបស់ព្រះវិញ្ញាណដែរ។ ការអត់ធ្មត់ និងការបន្ទាប់ខ្លួន គឺជាភស្តុតាងនៃសេចក្តីស្រឡាញ់។ ការបន្ទាបខ្លួនពិតប្រាកដគឺជាការលះបង់ខ្លួនឯង។ នេះគឺជាស្នូលនៃគុណតំលៃទាំងអស់»[1]

តុល្យភាពនៃការថែបំប៉ន ការបន្ទាបខ្លួន និងការបើកចំហរ អាចបង្កើតជាបរិយាកាសនៃការរៀនដ៏ស៊ីជម្រៅ។ ការរៀនដ៏ស៊ីជម្រៅទាមទារការតម្រង់រឿងសាំញ៉ាំ ដោយការវាយតំលៃគំនិតរបស់យើង ស្តាប់គំនិតនិងបទពិសោធន៍អ្នកដទៃ ហើយច្របាច់បញ្ចូលការទាំងនេះក្នុងជីវិតរបស់យើង។

ការអញ្ជើញរបស់ភីលីព ធ្វើឲ្យណាថាញែលវាយតំលៃការគិតរបស់គាត់ ដែលថាព្រះសង្គ្រោះគួរមកពី ភូមិដែលមានកេរ្តិ៍ឈ្មោះ។ ណាថាញែល មានការបើកចិត្ត និងទុកចិត្តគ្រប់គ្រាន់ដែលធ្វើឲ្យគាត់ចូលក្នុងពន្ធ័កិច្ចរបស់ព្រះគ្រីស្ទ។ ទោះបីជាវាមិនមានសុវត្ថិភាពរហូតក៏ដោយ ការធ្វើជាសាវក្សរបស់ព្រះគ្រីស្ទ គឺវាមានសុវត្ថិភាពគ្រប់គ្រាន់ដែលធ្វើឲ្យណាថាញែលកែរប្រែការគិតរបស់គាត់។ ដំណើរការនេះ ធ្វើឲ្យណាថាញែលរស់ក្នុងជីវិតថ្មី ដោយឲ្យគាត់តាំងចិត្តរៀនដើរតាមព្រះយេស៊ូវ ដែលជាព្រះសង្គ្រោះមកពីភូមិណាសារ៉ែត។ ដំណើរការនេះដូចជាសម័ញ្ញ តែជំហ៊ានដំបូងគឺពិបាកបំផុត។ ការវាយតំលៃការគិតរបស់យើង ហើយស្តាប់គំនិតរបស់អ្នកដទៃដែលមិនដូចគំនិតយើង។

---

[1] Steve W. Manskar and Diana L. Hynson, សេចក្តីស្រឡាញ់ឥតខ្ចោះ៖ការយល់ពីភាពឥតខ្ចោះរបស់គ្រីស្ទបរិសទ្ធ័ដែលលោកចនវេស្លីនិយាយ (Nashville: Discipleship Resources, 2003), (Q. 38 [2], 78).

ក្រុមជំនុំមានឱកាសក្នុងការបង្កើតការសន្ទនាខ្លាហាន។ ក្រុមជំនុំអាចដើរតួរជាអង្គការនៃការរៀនសូត្រ ព្រោះវាជាកន្លែងចាប់ផ្តើមការសន្ទនា ដែលនិយាយពីព្រះគុណព្រះ និងសេចក្តីពិត។ ក្រុមជំនុំគឺជាកន្លែងដែលយើងទទួលបានព្រះគុណព្រះ។ យើងអាចចូលរួមតុសន្ទនា ដោយទុកចិត្តថា អ្វីដែលយើងយកមកនិយាយ គឺជាបទពិសោធន៍នៃព្រះគុណព្រះ ពីព្រះវបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ បទពិសោធន៍របស់យើង មានបរិបទផ្សេងៗគ្នា។ ម្នាក់ៗជាផ្នែកមួយនៃរូបកាយព្រះគ្រីស្ទ យើងមានឱកាសក្នុងការបង្កើតបរិស្ថានដែលមានការសិក្សាស៊ីជម្រៅ។ កន្លែងដែលមានការសិក្សាបែបនេះ ជួយឲ្យក្រុមជំនុំបង្ហាញទៅពិភពលោកថា ក្រុមជំនុំរបស់យើងមានភាពរួបរួម និងសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក (យ៉ូហាន ១៣-១៤)។ កន្លែងសុវត្ថិភាពក្នុងវត្តមានរបស់ព្រះ គឺជាកន្លែងដែលការសន្ទនាពិតប្រាកដអាចកើតមានជាមួយអ្នកដែលមានគំនិតខុសពីយើង។

# ការសន្ទនា និងការជជែកដេញដោល

ការសន្ទនាខ្លាហាន គឺជាការអញ្ជើញមកពិភាក្សាគ្នា មិនមែនជាការជជែកដេញដោលទេ។ ការជជែកដេញដោល មានគោលដៅឲ្យគេជឿតាម ដើម្បីយកឈ្នះ ឬដើម្បីឈរលើខាងត្រូវ។ ការជជែកដេញដោល ខុសគ្នាពីការសន្ទនា។ ក្នុងការសន្ទនា លទ្ធផលគឺមិនច្បាស់ទេ។ គោលដៅគឺការយកចិត្តទុកដាក់លើភាពខុសគ្នា និងបើកចំហរសំរាប់គំនិតថ្មី។ ការសន្ទនាបើកសំដែងការគិតទុករបស់មនុស្ស និងបទពិសោធន៍ពិសេសៗរបស់គេ ដោយមានសង្ឃឹមថានឹងទទួលបានគំនិត និងឱកាសថ្មី។ ក្នុងវប្បធម៌របស់យើងដែលចង់បានអ្វីដែលខ្លីហើយខ្លឹម ការសន្ទនាដូចជាយឺតពេក ហើយមិនបានផលអ្វីសោះ។ ដូច្នេះហើយបានជាមនុស្សភាគច្រើនចូលចិត្តការជជែកដេញដោល។

ចំណងជើងរបស់យើង ការសន្ទនាខ្លាហាន គឺពិតណាស់ ព្រោះវាទាមទារសេចក្ដីខ្លាហានដើម្បីចូលក្នុង ការសន្ទនា។ វាទាមទារសេចក្ដីខ្លាហាន ដើម្បីសារភាពថាយើងខុស។ វាទាមទារភាពខ្លាហាន ដើម្បីទទួលបានទំនាក់ទំនងល្អ ជាជាងការចង់ឈ្នះចាញ់។ វាទាមទារភាពខ្លាហាន ដើម្បីពិនិត្យពីគំនិតរបស់ យើងឡើងវិញ។ វាទាមទារសេចក្ដីខ្លាហាន ក្នុងការប្រកាន់ជ្ជាប់ជំនឿរបស់យើងដោយការបន្ទាបខ្លួន និងការជួយជំរុញអ្នកដទៃទៅកាន់សេចក្ដីស្រឡាញ់។ វាទាមទារភាពខ្លាហាន ពេលដែលអ្នកដទៃ គេចាក់ចំចំនុចរសើបរបស់យើង ឬគេចាប់ផ្ដើមនិយាយបង្អាប់យើង ឬធ្វើឲ្យយើងឈឺចាប់។ ផ្លូវធមជាតិគឺ «វាយបក នៅទ្រឹង ឬរត់» ដើម្បីយើងមិនខ្វល់ពីអ្នកដែលមានគំនិតផ្ទុយពីយើង។

ជាគ្រីស្ទានដែលតែងតែប្រជុំគ្នាក្នុងពិធីលាងព្រះអម្ចាស់ ដែលយើងទទួលបានភាពរួបរួម ហើយទទួលបាននូវព្រះវត្តមានរបស់ព្រះ។ យើងគឺជារូបកាយរបស់ព្រះគ្រីស្ទ ដែលមានបទពិសោធន៍ គំនិត ជាតិសាសន៍ អាយុ និងភេទ ចំរុះ។ សម្បត់ដែលយើងធ្វើក្នុងពិធីជ្រមុជទឹក និងពាក្យពេជដែលយើងនិយាយ ក្នុងពិធីលាងព្រះអម្ចាស់ បានត្រាស់ហៅយើងឲ្យចូលរួមក្នុងតុតែមួយ។ វាទាមទាភាពខ្លាហាន ដូចលោកណាថាញែល ដើម្បីយើងមានចិត្តមកចូលរួមក្នុងតុសន្ទនា។ ហើយវាទាមទារភាពខ្លាហាន ក្នុងការដែលយើងនៅក្នុងតុសន្ទនា។

# កំឡាំងដែលធ្វើឲ្យយើងបែកបាក់

ការដែលយើងបានឃើញថាក្រុមជំនុំគឺជាផ្លូវមួយសម្រាប់ការសន្ទនាខ្លាហាន គឺជារឿងមួយ ប៉ុន្តែការដែលយើងចូលរួមក្នុងសន្ទនាខ្លាហាន គឺជារឿងមួយទៀត។ មានកំឡាំងជាច្រើនដែលធ្វើឲ្យយើងមិនស្ដាប់គ្នា។ បញ្ហាសង្គម

និងប្រតិកម្មជីវវិទ្យា និងខួរក្បាល គឺជាកត្តាសំខាន់ពេលយើងធ្វើការសន្ទនាពិបាកៗ។ ការដែលយើងស្គាល់ពីបញ្ហាទាំងនេះ អាចជួយយើងឲ្យរួចផុតពីកំឡាំងដែលធ្វើឲ្យយើងប្រកាន់ភ្ជាប់គំនិតខ្លួនឯង ហើយមិនបានគិតពីគំនិតអ្នកដទៃ។

# បញ្ហាសង្គម

វាមិនគួរឲ្យភ្ញាក់ផ្អើលទេ ដែលយើងជារូបកាយព្រះគ្រីស្ទមិនយល់ស្របគ្នា។ ជម្លោះ ឬការបែកបាក់ មិនមែនជារឿងថ្មីទេ។ ក្នុងព្រះគម្ពីរសញ្ញាថ្មី គ្រីស្ទបរិសទ័នៅទីក្រុងកូរិន ក៏មានការបែកបាក់។ ព្រះគម្ពីរកិច្ចការជំពូក១៥ បានកត់ត្រាពីអ្នកជឿព្រះគ្រីស្ទដំបូងមានជម្លោះ និងមានការជជែកដេញដោលពីរឿងកាត់ស្បែក សំរាប់អ្នកដែលទើបទទួលព្រះគ្រីស្ទ។

ក្នុងសៀវភៅដែលមានចំណងជើងថា ភាពមិនចុះសម្រុងគ្នាក្នុងព្រះគ្រីស្ទ លោកស្រី Christena Cleveland បានសរសេរពីបញ្ហាមួយចំនួនដែលកើតឡើងក្នុងក្រុមជំនុំ។ លោកស្រី Cleveland បានហៅបញ្ហាមួយថា «outgroup homogeneity effect» មានន័យថាការដែលយើងគិតថាមនុស្សដែលនៅក្រុម ផ្សេងគឺដូចគ្នាទាំងអស់។ ពួកគេដូចគ្នាទាំងអស់ តែអ្នកដែលនៅក្នុងក្រុមរបស់យើងគឺមានអត្តចរិកផ្សេងៗពីគ្នា។ ពេលដែលពួកគេគិតដូចគ្នា យើងមើលឃើញពីភាពខុសផ្លែកក្នុងក្រុមរបស់យើង។ ដូច្នេះយើងគិតជារួមថា អ្នកសេរីនិយម គិតដូចគ្នាទាំងអស់ ហើយយើងឃើញគំនិងផ្សេងៗគ្នាក្នុងក្រុមអភិរក្សនិយម។ យើងអាចប្រើឧទាហរណ៍នេះជាមួយប្រុស ស្រី កុមារ ចាស់ៗ ជាដើម។ ជាលទ្ធផល គឺយើងទទួលបានការគិតដែលមិនត្រឹមត្រូវ អំពីសេចក្តីជំនឿរបស់អ្នកដទៃ ឬយើងចោទប្រកាន់ថាអ្នកនេះមាន ជំនឿបែបនេះ ទាំងដែលគេមិនគិតបែបនោះផង។

កត្តាមួយទៀតដែលធ្វើឲ្យយើងបែកបាក់នោះ លោកស្រីCleveland ឲ្យ

ឈ្មោះថា «Gold Standard Effect»។ នេះគឺជាបញ្ហាដែលយើងនិយាយលើសពីការពិតចំពោះក្រុមអ្នកដែលមិនមានគំនិតដូចយើង ដែលនាំឲ្យក្រុមមួយជឿថាក្រុមគេគឺធម្មតា ត្រឹមត្រូវ ឬល្អជាង។ ដោយសារយើងគិតថា ជំនឿរបស់យើងត្រឹមត្រូវ នោះយើងគិតថា អ្នកដទៃទៀតគេមិនល្អដូចយើងទេ។ អកប្បកិរិយានេះធ្វើឲ្យយើង មិនស្តាប់ ឬមិនបើកចិត្តចំពោះគំនិតផ្សេងៗ ហើយគិតថាយើងមិនត្រូវការគំនិតមកពីក្រុមដទៃនោះទេ។ ក្នុងភាសាររបស់សាវក្សប៉ុល យើងគឺជាភ្នែកដែលនិយាយទៅកាន់ជើងថា យើងមិនត្រូវការឯងទេ (១កូរិនថូស ១២៖១៥)

តែការស្តាប់ល្អ មិនមែនជាថ្នាំព្យាបាលគ្រប់រឿងនោះទេ។ ទោះបីយើងស្តាប់ពិចារណាពីការគិតរបស់យើង ហើយពេញចិត្តគំនិតផ្សេងទៀត ក៏យើងមិនប្រាកដថាទទួលបានសាមគ្គីភាពដែរ។ ដូច្នេះគោលដៅនៃការសន្ទនាខ្លាហានមិនមែនសាមគ្គីភាព ដែលធ្វើឲ្យមានការគិតតែមួយនោះទេ។ ការសន្ទនាខ្លាហាន មានគោលដៅសំរាប់ការស្តាប់ដោយគោរព ទទួលស្គាល់វត្តមានរបស់ព្រះក្នុងអ្នកដទៃ និងរីកលូតលាស់ក្នុងព្រះគ្រីស្ទ ដែលយើងធ្វើគំរូនៃសេចក្តីស្រឡាញ់ សេចក្តីមេត្តា និងការជួយគ្នាទៅវិញទៅមក (យ៉ូហាន១៣-១៥)។ លោកស្រី Cleveland រំលឹកយើងថា «យើងត្រូវជឿថាក្នុងនាមជាអ្នកដើរតាមព្រះគ្រីស្ទ គឺមានន័យថាយើងយកចិត្តទុកដាក់អំពីអ្នកដើរតាមព្រះគ្រីស្ទផ្សេងទៀត រួមទាំងអ្នកដែលមានគំនិតខុសពីយើងផងដែរ។ យើងត្រូវជឿថា ក្នុងនាមជាអ្នកដើរតាមព្រះគ្រីស្ទ យើងត្រូវតែប្រកាន់ ភ្ជាប់ភាពជារូបកាយរបស់ព្រះគ្រីស្ទ។»[2]

---

[2] Christena Cleveland, ភាពបែកគ្នាក្នុងព្រះគ្រីស្ទ (Downers Grove, Intervarsity Press, 2013), 97.

# បញ្ហានយោបាយ

មិនមែនជារឿងថ្មីនោះទេ ដែលថាជនជាតិអាមេរិកាំង គឺមានការបែងចែកនយោបាយ។ ក្រុមស្រាវជ្រាវ Pew Research បានបង្ហាញថាយើងមានការបែកចែករវាងអ្នកអភិរក្សនិយម និងអ្នកសេរីនិយម ជាង៤០ឆ្នាំមកនេះ។ លោក Michael Slaughter និង លោកCharles Gutenson បានសរសេក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា ចោរប្លន់[3] ការបែងចែកនេះធ្វើឲ្យមានការប៉ះពាល់ដល់ក្រុមជំនុំ ពេលដែលយើងអនុញ្ញាតិឲ្យនយោបាយជះឥទ្ធិពលដល់វិជ្ជាព្រះ។

ការលំអៀង និងការគិតស្មាន របស់យើង ជះឥទ្ធិពលដល់ការអានព្រះគម្ពីររបស់យើង ហើយធ្វើឲ្យយើងមានការបែកបាក់កាន់តែខ្លាំង។ ជារឿយៗយើងនិយាយថា ពួកគេមិនបានអានព្រះគម្ពីរដោយសេចក្តីជំនឿ ឬដោយត្រង់ ឬដោយមានព្រះក្នុងខ្លួនទេ។ ការដែលយើងឮការបកស្រាយព្រះគម្ពីររបស់អ្នកដទៃធ្វើឲ្យយើងមិនពេញចិត្ត ហើយមិនចង់ស្តាប់។ ពេលនោះឯងដែលយើត្រូវដឹងថា យើងគួរធ្វើដូច លោកណាថាញែល។ ព្រោះពេលនេះអាចជាឪកាសដែលធ្វើឲ្យយើងរីកលូតលាស់។

# បញ្ហាប្រសាទ

ពេលយើងជួបប្រទះគំនិតដែលធ្វើឲ្យយើងរន្ធត់ ឬធ្វើឲ្យយើងគិតសារឡើងវិញពីគោលជំនឿរបស់យើង ប្រត្តិកម្មធម្មជាតិរបស់យើងគឺមិនមែនជាការបើកចិត្ត

---

[3] Charles E. Gutenson and Mike Slaughter, ចោរឆក់៖ការឆ្លើយតបចំពោះភាពបែកបាក់របស់ក្រុមជំនុំ (Nashville: Abingdon Press, 2012).

នោះទេ។ បើយើងជឿលើជំនឿរបស់យើងកាន់តែជ្រៅ នោះបរិបទដែលធ្វើឲ្យយើងគិតសារឡើងវិញពីជំនឿរបស់យើង (មានសុវត្ថិភាព ឬមិនមាន) និងរបៀបដែលគេសួរដេញដោលយើង អាចធ្វើឲ្យយើងប្រកែកយកឈ្នះ។

បើយើងមានការព្រួយ ខួរក្បាលរបស់យើងបញ្ជូនសញ្ញាពេញរាងកាយរបស់យើង ដើម្បីឲ្យយើងត្រៀមចម្បាំង។ ខួរក្បាលរបស់យើងចាប់ផ្ដើមធ្វើការតាមរបៀបធ្វើម៉េចឲ្យរស់ ដោយមិនបានប្រើផ្នែកគិត។ ក្នុងការពិភាក្សាក្ដៅគគុគមួយ យើងប្រហែលឆ្ងល់ថា ហេតុអ្វីយើងនិយាយអ្វីដែលយើងបាននិយាយ ឬឆ្ងល់ថាហេតុអ្វីយើងមានគំនិតបែបនេះ។ ជាទូទៅគឺដោយសារការព្រួយ ធ្វើឲ្យយើងគ្មានលទ្ធភាពក្នុងការគិត។ ជាជាងការដែលយើងស្ថិតក្នុងសភាពចង់ដឹងចង់ឮ ហើយអាចមើលឃើញពីភាពឆ្នៃប្រឌិត យើងស្ថិតក្នុងភាពវាយបក។ ហើយយើងមិនដឹងខ្លួនទេ។

ដើម្បីយើងអាចទទួលបានភាពចង់ដឹង យើងត្រូវតែមានអារម្មណ៍សុវត្ថិភាព។ លើកក្រោយ ពេលដែលអ្នកដឹងថា អ្នកកំពុងតែស្ថិតក្នុងស្ថានភាពក្ដៅគគុគ សូមចាំថាពេលនោះអ្នកមិនមានមានសុវត្ថិភាពទេ។ ជាជាងការដែលយើងដោះស្រាយដោយកណ្ដាប់ដៃ សូមយើងសំគាល់មើលពីកំរិតព្រួយបារម្ភណ៍ នៃការសន្ទនានេះ។ នោះ សូមកុំខឹង គឺត្រូវចង់ដឹងចង់ឮវិញ។

# ការទុកចិត្ត

រនាំងធំមួយនៃការទទួលបានការសន្ទនាដែលមានផលផ្លែ គឺការទុកចិត្ត។ បើគ្មានការទុកចិត្ត នោះវាគ្មានសុវត្ថិភាពទេ។ បើគ្មានសុវត្ថិភាព យើងនឹងមិនបើកចំហរសំរាប់ការសន្ទនាដែលមានន័យនោះទេ។

ការមិនទុកចិត្តនាំឲ្យមានការសន្មត់ខុស ឬអាចធ្វើឲ្យមានការយល់ច្រឡំ

ទៀតផង។ បើយើងជឿថា គ្រប់អ្នកដែលគាំទ្រច្បាប់មិនឲ្យប្រើអាវុធ សុទ្ធតែជាអ្នកដែលស្រឡាញ់សន្តិភាព និងសង្គមនិយម នោះពេលដែលយើងឮអ្នកណាម្នាក់និយាយគាំទ្រច្បាប់មិនឲ្យប្រើអាវុធ នោះអាចធ្វើឲ្យយើងធ្វើការសន្មត់ខុស។ ការពិតនោះគឺថា អ្នកខ្លះគាំទ្រច្បាប់មិនឲ្យប្រើអាវុធ តែមិនស្រឡាញ់សន្តិភាព និងសង្គមនិយមទេ។ ការចូលរួមក្នុងការសន្ទនាខ្លាហាន វាទាមទារឲ្យយើងឈប់វាយតំលៃអ្នកដទៃ នោះទើបយើងអាច យល់ពីគំនិតរបស់គេ។ បើយើងគិតថា កូនដែលមិនរៀបចំគ្រែរបស់គេពេលងើបពីដេកសុទ្ធតែមិនស្តាប់បង្គាប់ឳពុកម្តាយ នោះយើងនឹងភ្លេចគិតថា ប្រហែលជាគេមានការងារត្រូវធ្វើច្រើនពេក។

ជាគ្រីស្ទាន ការដែលយើងចង់សន្ទនាខ្លាហាន យើងគឺតែមានគំនិតមួយថា យើងគ្រប់រូបមិនល្អគ្រប់ដប់នោះទេ ហើយសុទ្ធតែកំពុងស្វាងខ្លួនឲ្យបានប្រសើរឡើង។ នេះមានន័យថា យើងកំពុងតែផ្តល់ព្រះគុណព្រះ ដល់គ្នាទៅវិញទៅមក ដោយព្យាយាមមិនកាត់ទោសអ្នកទៃ ហើយចៀសពីការគិតថា មនុស្សសុទ្ធតែមានបទពិសោធន៍ជីវិតដូចគ្នា។ យើងក៏ចាប់អារម្មណ៍ដែរថា ពេលដែលយើងមានភាពលំអៀង នោះការទុកចិត្តគ្រាន់តែជាសេចក្តីគាំទ្ររគោលជំនឿរបស់យើងតែប៉ុណ្ណោះ។

ពេលដែលយើងខឹង ឬពេលដែលយើងគិតអីមិនចេញ យើងត្រូវតែថយក្រោយមួយជំហាន ហើយចង់ដឹងចង់ឮ។ យើងត្រូវសួរ «ហេតុអ្វីគេគិតបែបនេះ ដែលវាខុសពីគំនិតរបស់យើងទាំងស្រុង?» ក្នុងសៀវភៅដែលមានចំណងជើងថា បែរកគ្នា លោកស្រី Margaret Wheatley បានសរសេរថា «ការចង់ដឹងចង់ឮគឺជាជំនួយឲ្យមានការសន្ទនាល្អ។ វាងាយណាស់ដែលយើងប្រាប់រឿងយើង ចែកចាយពីសុបិន្ត និងសេចក្តីភ័យខ្លាច ពេលដែលយើងគិតថាអ្នកដទៃចង់ឮរឿងរបស់យើង»[4]

---

[4] Margaret J. Wheatley, បែរកគ្នា (San Francisco, Berrett-Koehler Publishers, 2002), 30.

# ដំបូន្មានល្អ

បន្ទាប់ពីបានគិតពីហេតុផលនៃការសន្ទនាខ្លាហាន និងបញ្ហាមួយចំនួនដែលធ្វើឲ្យយើងមិនត្រូវគ្នា យើងគួរស្វែងរកជំហានអនុវត្ត ដើម្បីឲ្យទំនាក់ទំនងរបស់យើង និងការសន្ទនាក្នុងក្រុមជំនុំ ក្លាយជាកន្លែងសុវត្ថិភាព ក្នុងការរៀនសូត្រ។ ជំហានខ្លះនៅលើគោក ហើយស្រួល ដូចជាសេចក្ដីអធិស្ឋាន។ ជំហានមួយចំនួន មិនងាយស្រួល ហើយទាមទារឲ្យយើងមានចិត្តខ្លាហាន និងហ៊ានទទួលខុស។

# សេចក្ដីអធិស្ឋាន

និយមន័យនៃពាក្យអធិស្ឋានដែលខ្ញុំចូលចិត្តគឺ «ការនៅក្នុងវត្តមានរបស់ព្រះដោយចិត្តចង់»។ សេចក្ដីអធិស្ឋានគឺជាការដែលយើងនាំខ្លួនយើងចូលចំពោះព្រះវត្តមានព្រះ ដោយនៅស្ងៀម និងបន្ទាបខ្លួន។ ឧទាហរណ៍ដូចជាលោកយ៉ូប (យ៉ូប៤០៖១-៥) ឬ អេលីយ៉ា (១ពង្សាវត្តាក្សត្រ១៩៖១១-១៣) ការស្វែងរក ព្រះទ័យរបស់ព្រះ ពេលយើងព្យាយាមធ្វើឲ្យមានភាពស្ងប់ស្ងាត់ នៅស្ងៀម និងស្ដាប់។

អំឡុងពេលអធិស្ឋាននេះ យើងធ្វើឲ្យខ្លួនយើងចូលមកចំពោះព្រះវិញ្ញាណបរិសុទ្ធ។ ត្រង់នេះ គឺព្រះបើកសម្ដែងមកកាន់យើង កន្លែងដែលយើងមានភាពអត្មានិយម ឬប្រត្តិកម្មដោយសេចក្ដីភ័យខ្លាច។ សេចក្ដីអធិស្ឋានអាចជាកន្លែងដែលព្រះវិញ្ញាណបរិសុទ្ធដឹកនាំយើង ទៅកាន់ទីមួយដែលមានពេញដោយឱកាស ដែលយើងអាចធ្វើការពិចារណា។

យើងតែងគិតថា សេចក្តីអធិស្ឋានគឺជាការនៅដាច់ដោយឡែក តែការនៅជាក្រុមអាចជាពេលដែលយើងធ្វើឲ្យមានសេចក្តីអធិស្ឋានស្ងៀមស្ងាត់ផងដែរ។ សូមរកពេលស្ងៀមស្ងាត់ ហើយដឹកនាំការអធិស្ឋានជាក្រុម ដែលធ្វើឲ្យការដោះស្រាយការងារសាំញ៉ាំ ក្លាយជាពេលដ៏មានន័យបំផុតសំរាប់យើង។ វាអាចជាពេលដែលយើងបើកចំហរដាក់គ្នា ដើម្បីនាំគ្រប់គ្នាធ្វើតាមមាគារបស់ព្រះជាជាងផ្លូវរបស់ខ្លួនឯង។

# ការចាប់ផ្តើមពីខ្លួនឯង

កន្លែងដែលល្អបំផុតដើម្បីចាប់ផ្តើមការសន្ទនាពិបាកៗ គឺជាការដែលយើងផ្តោតលើចំនុចមួយដែលយើង អាចគ្រប់គ្រងបាន គឺខ្លួនឯង។ ដំបូន្មានមួយនេះ គឺមានតំលៃណាស់។ បើយើងមិនដឹងពីការនេះទេ ទំលាប់របស់យើងអាចធ្វើគ្មានការរីកចំរើនចំពោះការសន្ទនាទេ ពីព្រោះយើងមិនដឹងពីបញ្ហាខាងក្នុង របស់យើង។

យើងអាចបន្ទោសអ្នកដទៃថា គេជាអ្នកធ្វើឲ្យយើងខឹង។ ការពិតនោះគឺថា យើងខ្លួនឯងជាអ្នកទទួលខុស ត្រូវចំពោះអារម្មណ៍ខ្លួនឯង។ ទោះជាអ្នកដទៃគេចាក់ដោតយ៉ាងណា ឬនិយាយបញ្ឈឺយើងយ៉ាងណា យើងត្រូវតែគ្រប់គ្រងប្រតិកម្មរបស់យើង។

តម្រុយមួយសំរាប់ការសន្ទនាដែលមានប្រយោជន៍ ដែលធ្វើគ្រប់គ្នាទទួលខុសត្រូវចំពោះគំនិតរបស់គេ នោះគឺការប្រើពាក្យថា «ខ្ញុំ»។ ពាក្យថា «អ្នក» ជាទូទៅស្តាប់ទៅដូចជាឈ្លើយ។ ជាជាងនិយាយថា «ហេតុអ្វីអ្នកមិនដែលប្រាប់ខ្ញុំថាអ្នកស្រឡាញ់ខ្ញុំដូចមុន?» យើងគួរនិយាយថា «ខ្ញុំចង់បានការសរសើរច្រើនជាងនេះ»។ ជាជាងពាក្យថា «ម្តាយក្មេកអ្នកឯងចង់រករឿងខ្ញុំ» យើងគួរនិយាយថា «ខ្ញុំចង់ដឹងថាហេតុអ្វីអ្នកគិតដូច្នេះ។ ខ្ញុំមិនយល់ទេ»

យើងអាចសួរខ្លួនឯង «ហេតុអ្វីខ្ញុំមានប្រតិកម្មបែបនេះ?» វាប្រហែលជាមកពីអំឡុងពេល ឬបន្ទាប់ពីការសន្ទនា អ្នកមានកំហឹងខ្លាំងជាងការដែលអ្នកគិត។ អ្នកមិនបានបង្ហាញជំហ៊ររបស់អ្នកច្បាស់លាស់ ឬសួរឲ្យបានច្បាស់ អ្នកទៅជាមិនចេញស្ដី ឬបញ្ចេញកំហឹងតាមពាក្យសំដីរបស់អ្នក។ សូមប្រើពេលគិតពីការសន្ទនាដែលអ្នកមានការពីមុន ដែលអ្នកមិនដូចជាអ្វីដែលអ្នកចង់បាន ហើយសួរខ្លួនឯងថា «ហេតុអ្វីខ្ញុំមានប្រតិកម្មបែបនេះ?»

«តើខ្ញុំខ្លាចអី?» ចំណាយពេលគិតពីប្រតិកម្មរបស់យើង អាចបង្ហាញពីបញ្ហានៃការសន្ទនាពិបាកៗ ពេលយើងដោះស្រាយបញ្ហាក្នុងគ្រួសារ និងការដែលយើងធ្វើឲ្យមានភាពតានតឹង ឬជួនកាលគ្រាន់តែញាំអាហារមិនឆ្ងាញ់។ មិនថាបញ្ហាអ្វីទេ កន្លែងល្អបំផុតក្នុងការចាប់ផ្ដើមសន្ទនាគឺចេញពីការសារភាព។ យើងមិនល្អឥតខ្ចោះ ហើយកំពុងបន្តរីកលូតលាស់ក្នុងព្រះគ្រីស្ទ (ភីលីព ១៖៦).

វិធីមួយដើម្បីផ្ដោតលើចំឡើយរបស់យើង មុនពេលនិងអំឡុងពេលសន្ទនាខ្លាហាន គឺការដែលយើងដឹងច្បាស់ថា យើងចង់បានអីពីការសន្ទនានេះ។ តើយើងកំពុងតែចង់ដឹងច្បាស់ពីរបៀបធ្វើជាឪពុកម្ដាយ មែនទេ? ឬចង់ឈ្នះការជជែកដេញដោល? ឬចង់ត្រូវ? ឬត្រូវបាំងអសន្តិសុខ? ឬដើម្បីរៀនពីគំនិតអ្នកដទៃ ឬប្រធានបទណាមួយ? ជារឿយៗ យើងដឹងថា យើងមានការសន្ទនាច្របូកច្របល់។ ការបញ្ជាក់ពីគោលដៅច្បាស់លាស់ជួយឲ្យយើងមានគោលជំហ៊រច្បាស់លាស់ ហើយធ្វើឲ្យយើងអាចគ្រប់គ្រងលើអារម្មណ៍ខ្លួនឯងបាន។

ដើម្បីផ្ដោតលើគោលដៅការសន្ទនាណាមួយ អ្នកនិពន្ធសៀវភៅ ការសន្ទនាសំខាន់៖សំភារៈសំរាប់ការនិយាយពេលមានបញ្ហាធំ បានលើពីសំនួរល្អបី ១ «តើខ្ញុំចង់បានអ្វីសម្រាប់ខ្លួនឯង?» ២ «តើខ្ញុំចង់ធ្វើអ្វីសម្រាប់អ្នកដទៃ» ៣ «តើខ្ញុំចង់ឲ្យទំនាក់ទំនងនេះទៅជាយ៉ាងណាង»[5]

---

[5] Kerry Patterson, Joseph Grenny, Ron Mcmillian, Al Switzler, ការសន្ទនាសំខាន់៖សំភារៈសំរាប់ការនិយាយពេលមានបញ្ហាធំ (New York: Lagrawhill, 2002), 34.

យើងអាចសួរមួយទៀត «បើតាមដែលខ្ញុំអាចគិតបាន តើព្រះចង់បានអ្វី ក្នុងស្ថានភាពនេះ?»

# ការសន្ទនាខ្លាហានក្នុងក្រុមជំនុំ

ធាតុដែលមានឥទ្ធិពលបំផុតក្នុងការមានការសន្ទនាខ្លាហានក្នុងក្រុមជំនុំ គឺជាសមត្ថភាពក្នុងការអាចបង្កើតបរិស្ថាននៃការទុកចិត្ត និងបដិសន្ធារកិច្ច។ បើមនុស្សគិតថាមានអ្នកកំពុងស្ដាប់ និងមានការគោរពពីអ្នកដទៃ នោះគេនឹងបញ្ចេញយោបល់របស់គេ។ ប៉ុន្តែបើគ្មានការស្ដាប់និងការគោរព នោះគេនឹងមិនបញ្ចេញគំនិតគេទេ។

មានវិធីមួយចំនួន ដើម្បីឲ្យការនេះកើតឡើង (សូមមើលធនធានខាងក្រោយកូនសៀវភៅនេះ  និងគេហទំព័រការសន្ទនាខ្លាហាន)។ បើអាច ក្រុមជំនុំគួរបង្កើតក្រុមមួយ ដើម្បីរៀបចំការសន្ទនានេះឡើង។ កត្តាដូចជា បរិស្ថាន បន្ទប់ តុមូលធំ របៀបវិរៈក្នុងការសន្ទនា ទាន និងនិមិត្តរូបសាសនា  គឺជាការរំលឹក ពីព្រះវត្តមានរបស់ព្រះ ក្នុងពេលសន្ទនា។ ការបង្ហាញ និងការបញ្ជាក់ពីការរំពឹងទុក និងរបៀបវិរៈសំរាប់ការសន្ទនា អាចជាការរំលឹកក្នុងអំឡុងពេលសន្ទនា និងការរំពឹងពីដំបូង ថាតើការសន្ទនានេះនឹងកើតឡើងយ៉ាងណា។

កត្តាសំខាន់មួយទៀត គឺជាតួនាទីអ្នកសម្របសម្រួល។ បើអ្នកសម្របសម្រួលមិនទទួលបានការទុកចិត្តពីដៃគូសន្ទនា និងមិនមានជំនាញក្នុងការសម្របសម្រួលការសន្ទនាដ៏ល្អមួយ (ឧទាហរណ៍ថា គាត់តែងគិតថាគាត់មានគំនិតសំខាន់) នោះគាត់នឹងធ្វើឲ្យការសន្ទនាគ្មានន័យ។ ធ្វើយ៉ាងណាឲ្យគ្រប់ភាគីឃើញពីភាពប្រាកដប្រជា និងការគិតគូរបានជាក់លាក់ ដែលត្រូវបានរៀបចំយ៉ាងហ្មត់ចត់ ដើម្បីឲ្យគេបានឃើញពីភាពស្រទន់នៃការសន្ទនានេះផងដែរ។

# ការសន្ទនាខ្លាហានសម្រាប់ទំនាក់ទំនងផ្ទាល់ខ្លួន

ជំនាញដែលប្រើសំរាប់ក្រុម ក៏មានប្រយោជន៍សំរាប់ការសន្ទនាខ្លាហានសម្រាប់ទំនាក់ទំនងផ្ទាល់ខ្លួនផងដែរ។ យើងបានពិភាក្សារួចហើយពីសំនួរថា «តើខ្ញុំចង់បានអ្វីប្រាកដ?» វិធីសាស្ត្រមួយទៀត ពេលអ្នកសង្កេតឃើញថា កំរិតនៃការតានតឹងកំពុងរីកឡើង នោះគួរព្យាយាមយល់ថាតើអ្នកដទៃកំពុងគិតពីអ្វី ជាជាងការដែលយើងព្យាយាមពន្យល់គំនិតរបស់យើង។

ដើម្បីឲ្យការសន្ទនាបន្ថយល្បឿនបន្តិច សូមចាត់ទុកថាការសន្ទនាគឺជាចំនុចចាប់ផ្តើមនៃការនិយាយគ្នា ជាជាងការដែលយើងគិតថា នេះគឺជាពេលតែមួយដែលយើងត្រូវនិយាយពីបញ្ហា។ សមជាមិត្តភក្រ័ ដើម្បីធ្វើឲ្យគំនិតរបស់យើងមានភាពច្បាស់លាស់ ហើយក៏អាចសំលាងជំនាញនៃការសន្ទនារបស់យើង។

ជួនកាលគំនិតនៃការសន្ទនាអាចពិការ ព្រោះអ្នកមិនដឹងថាអ្នកដទៃនឹងមានប្រត្តិកម្មយ៉ាងម៉េច ឬអ្នកត្រូវចាប់ផ្តើមពីណា។ ការជឿជាក់ថា វាមានប្រយោជន៍ដែលអ្នកចូលមកសន្ទនា ហើយព្រះវត្តមានរបស់ព្រះនឹងមានសម្រាប់អ្នក ពេលដែលអ្នកស្តាប់និងនិយាយពីសេចក្តីត្រូវការរបស់អ្នក ហើយគួរត្រូវហ៊ានបញ្ចេញភាពខ្លាហាន។

ពេលយើងឃើញការសន្ទនាខ្លាហាន ជាការរីកចំរើនជាសាវក្សរបស់ព្រះគ្រីស្ទ យើងដឹងថាជំនាញ និងការអនុវត្តទាំងនេះ ជួយយើងម្នាក់ៗ និងជាសហគមន៍នៃអ្នកជំនឿ ដែលដើរតាមសេចក្តីស្រឡាញ់របស់ ព្រះគ្រីស្ទ ដែលទ្រង់ហៅយើងជារូបកាយទ្រង់ (យ៉ូហាន ១៥៖១២; ១៧)

# ជាចុងក្រោយ

តើនឹងមានអ្វីកើតឡើង បើយើងសំរេចចិត្តចូលសន្ទនាដោយខ្លាហាន? យើងប្រហែលជាត្រូវលេបសេចក្ដីអំនួតរបស់យើង។ យើងប្រហែលជាត្រូវបញ្ចេញពីសេចក្ដីភ័យខ្លាចបំផុតរបស់យើង។ យើងប្រហែលត្រូវចូលរួមក្នុងការនិយាយពីភាពឈឺចាប់ និងការគួរឲ្យខ្លាច ជាមួយមនុស្សដែលយើងជិតស្និទ្ធជាទីបំផុត។ យើងក៏ប្រហែលជាត្រូវរៀនបញ្ចេញពីការចង់បានរបស់យើង ឲ្យច្បាស់ ដើម្បីឲ្យអ្នកដទៃយល់។ យើងប្រហែលជាត្រូវរៀនស្ដាប់គំនិតអ្នកដទៃ ដែលជំរុញឲ្យយើងទៅកាន់ទីកាន់តែខ្ពស់ ក្នុងទំនាក់ទំនងជាមួយព្រះ និងអ្នកដទៃ។ សំនួរដ៏គួឲ្យខ្លាចនោះអាចជា «តើនឹងមានអ្វីកើតឡើងបើយើងបរាជ័យ ក្នុងការចូលរួមសន្ទនាដោយខ្លាហាន?»

ការរីកចំរើនជាសាវក្ស ជាទូទៅទាមទារការខំប្រឹងប្រែងរបស់យើង។ វាទាមទារឲ្យយើងមានភាពខ្លាហានក្នុងការរៀបខ្លួនឯង ឲ្យមានការបើកចំហរ និងចង់ដឹងចង់ឮ ដូចជាលោកណាថាញែល និងដូចជាព្រះគ្រីស្ទ ក្នុងការផ្ដល់ព្រះគុណ និងសេចក្ដីពិត។ យើងសូមបញ្ចប់ជាមួយដំបូន្មានរបស់លោកស្រី Margaret Wheatley ថា «ខ្ញុំសង្ឃឹមថាអ្នកនឹងចាប់ផ្ដើមការសន្ទនា ស្ដាប់ពីអ្វីដែលថ្មី។ ស្ដាប់ឲ្យបានល្អបំផុត ដើម្បីដឹងពីអ្វីដែលខុសគ្នា និងពីអ្វីដែលធ្វើឲ្យអ្នកភ្ញាក់ផ្អើល។ សូមសង្កេតមើលថា ការអនុវត្តបែបនេះ នឹងធ្វើឲ្យអ្នករៀនបានអ្វីដែលថ្មីខ្លះ»[6]

[6] Wheatley, 36.

**DISCIPLESHIP MINISTRIES**
The United Methodist Church

កូនសៀវភៅនេះត្រូវបានផលិតដោយពន្ធ័កិច្ចអ្នកដឹកនាំ។
បើលោកអ្នកត្រូវការស្វែងយល់ពីធនធានរបស់ពន្ធ័កិច្ចអ្នកដឹកនាំ សូមចូល
ទៅកាន់គេហទំព័រខាងក្រោម៖

**www.umcdiscipleship.org/leadership-resources**

1908 Grand Avenue, Nashville, TN 37212
UMCdiscipleship.org
877.899.2780
info@UMCdiscipleship.org

COM907